**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...០៤...សរណន

# សារាចរណែនាំ
## ស្តីពី
## ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១២០ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ឧសភា ឆ្នាំ ២០០៦

≈≈≈≈≈≈≈

ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិ ដែលចាប់ផ្តើមនាឆ្នាំ ១៨៨៦ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពនៃលក្ខខណ្ឌការងារ និងជីវភាពរស់នៅរបស់ប្រជាពលករ។ នៅកម្ពុជា ទិវាពលកម្មអន្តរជាតិថ្ងៃទី ០១ ខែ ឧសភា ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំតាំងពីឆ្នាំ ១៩៧៩ ហើយមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានកំណត់យកថ្ងៃទី ០១ ខែ ឧសភា គឺជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សម្រាករបស់មន្ត្រីរាជការ ក៏ដូចជាកម្មករ និយោជិត។ បណ្តាស្ថាប័នរដ្ឋ និងសហគ្រាស គ្រឹះស្ថានជាច្រើនបានរៀបចំទិវានេះក្នុងបរិយាកាសសប្បាយរីករាយ និងសាមគ្គីភាព។

ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងអនុវត្តលក្ខខណ្ឌការងារ ធានាសិទ្ធិប្រយោជន៍កម្មករ និយោជិត តាមច្បាប់ស្តីពីការងារ ព្រមទាំងបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិខាងការងារចំនួន ១៣ ក្នុងនោះមានអនុសញ្ញាស្នូលចំនួន ៨។ សិទ្ធិសហជីព សិទ្ធិកូដកម្ម ឡុកអៅ ត្រូវបានអនុវត្តយ៉ាងពេញលេញ។ គណៈកម្មការប្រឹក្សាការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាយន្តការត្រីភាគីត្រូវបានបង្កើតឡើង និងអនុវត្តតួនាទីភារកិច្ចយ៉ាងសកម្មតាមការកំណត់នៃច្បាប់ និងធានាបាននូវភាពជាដៃគូរបស់គ្រប់ភាគីពាក់ព័ន្ធក្នុងវិស័យការងារ។ ចំនុចល្អទាំងឡាយនេះ គឺជាប្រៀបខ្លាំង និងកេរ្តិ៍ឈ្មោះល្អរបស់ទំនិញកម្ពុជាសម្រាប់ទីផ្សារអន្តរជាតិកន្លងមក។

ឆ្នាំ ២០០៦ នេះ យើងទាំងអស់គ្នាត្រូវកំណត់យកស្មារតី ទិវា ០១ ឧសភា ជាថ្ងៃប្តេជ្ញាចិត្តលើកកម្ពស់ការគោរពច្បាប់ស្តីពីការងារ សំដៅទទួលបានលក្ខខណ្ឌការងារល្អ ផលិតភាពការងារខ្ពស់ ដែលជាការរួមចំណែកបង្កើនគុណភាពផលិតផលសម្រាប់ការប្រកួតប្រជែង ដើម្បីទិសដៅរួមគឺ ការអភិវឌ្ឍ និងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។

អាស្រ័យហេតុនេះ ដើម្បីឱ្យការប្រារព្ធខួបលើកទី ១២០ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ឧសភា ឆ្នាំ ២០០៦ នេះ ប្រព្រឹត្តទៅបានល្អ រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំ ដូចខាងក្រោមនេះ :

១- ក្រសួងព័ត៌មាន ត្រូវណែនាំឱ្យម៉ាស៊ីនឃោសនារបស់រដ្ឋ និងឯកជនទទួលផ្សព្វផ្សាយសារលិខិតរបស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ១២០ នៃទិវាពលកម្មអន្តរជាតិ

ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៦ ជូនសង្គមជាតិទាំងមូលយល់ពីអត្ថន័យនៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា គឺជា សមិទ្ធិរបស់មនុស្សជាតិ និងជាព្រឹត្តិការណ៍អន្តរជាតិវិស័យការងារ ដែលបានបង្កើតនូវលក្ខខណ្ឌការងារជាស្តង់ដា សម្រាប់ការអនុវត្តរហូតសព្វថ្ងៃនេះ ព្រមទាំងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា អំពីការវិនិយោគ ការបង្កើតការងារធ្វើ លក្ខខណ្ឌការងារល្អ ការប្រកួតប្រជែង និងការអភិវឌ្ឍប្រទេសជាតិ ។

២- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចាត់ចែងការងារមួយចំនួន ជាអាទិ៍ :

- បំផុសការជួបសំណេះសំណាល ការជួបជុំជប់លៀងកំសាន្តសប្បាយ ការដើរកំសាន្ត តាមរូបភាព និងលទ្ធភាពរៀងៗខ្លួនរបស់សហគ្រាស គ្រឹះស្ថានដើម្បីបង្កបរិយាកាសសាមគ្គីភាព ភាតរភាព រវាងកម្មករ និយោជិត និងនិយោជក ។
- សហការជាមួយសាលាក្រុងភ្នំពេញ ក្នុងការចងបដា ពាក្យស្លោក នៅតាមដងវិថីសំខាន់ៗនៃរាជធានីភ្នំពេញ ក្នុងអត្ថន័យណែនាំការប្រារព្ធទិវាពលកម្មអន្តរជាតិថ្ងៃទី ០១ ខែ ឧសភា ដើម្បីបំផុសស្មារតីសាមគ្គីភាព យោគយល់គ្នា គោរពសិទ្ធិ និងផលប្រយោជន៍រួមរបស់កម្មករនិយោជិត និងនិយោជក ។ ចំពោះក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងសហគ្រាសគ្រឹះស្ថានឯកជន គ្រប់ខេត្ត-ក្រុង ត្រូវចងបដាពាក្យស្លោកថា "អបអរសាទរខួបអនុស្សាវរីយ៍លើកទី ១២០ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៦" នៅពីមុខអាគាររៀងៗខ្លួន ។

៣- ក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធរខេត្ត ក្រុង និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវណែនាំកម្លាំងមានសមត្ថកិច្ចរបស់ខ្លួនក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងឱកាសទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ឧសភា ឆ្នាំ ២០០៦ នេះ ។

៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយថវិកាឱ្យបានទាន់ពេលវេលា និងតាមគោលការណ៍កំណត់ ដើម្បីធានាការចាត់ចែងដំណើរការរៀបចំសមស្របតាមគោលបំណង និងសំណូមពរ ។

រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវដល់អង្គការវិជ្ជាជីវៈ សមាគម និងប្រជាពលរដ្ឋទាំងអស់ ចូលរួមអបអរទិវាពលកម្មអន្តរជាតិ ០១ ឧសភា ក្នុងក្តីសោមនស្សរីករាយ សាមគ្គីភាព ភាតរភាព ដើម្បីការអភិវឌ្ឍប្រទេសជាតិយើង ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់ខេត្ត-ក្រុង រៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន និងខេត្ត-ក្រុង*
- *ឯកសារ-កាលប្បវត្តិ*